**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**
សាលក្រមរដ្ឋប្បវេណីលេខៈ៣៥ (ត)
ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តតាកែវ**

-បានទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ និងប្រកាសសាលក្រមនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០២៤ ដោយមានសមាសភាពចូលរួមៈ

**ចៅក្រម**

លោក [redacted] អនុប្រធាននិងជាចៅក្រមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

ដើម្បីទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខៈ១៩៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០២៣ ដែលមានកម្មវត្ថុៈ

ដើមចោទប្តឹងសុំៈ

១-សុំមោឃភាពកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដី) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងឈ្មោ[redacted] ធារិទ្ធ និងឈ្មោ[redacted] គីមហេង ឈ្មោះ [redacted] សុផល ។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

ពាក្យសុំកែតម្រូវពាក្យបណ្តឹងរបស់មេធាវីដើមចោទៈ

ក-សុំរំលាយកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដី) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងឈ្មោះ [redacted] ធារិទ្ធ និងឈ្មោះ [redacted] គីមហេង ឈ្មោះ [redacted] សុផល (រំលាយឆន្ទៈរបស់ឈ្មោះ [redacted] សុផល) ។

ខ-ទាមទារសំណងនៃការខូចខាតចំនួន១០.០០០$ (ដប់ពាន់)ដុល្លារ និងប្រាក់កក់ទាំងអស់ដែលកូនក្តីរបស់ខ្ញុំបានទទួលកន្លងមកពីភាគីអ្នកទិញ(ដី) ចាត់ទុកជាផលប្រយោជន៍របស់កូនក្តី ។

គ-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

បណ្តឹងតបៈ

១-ទទួលស្គាល់កិច្ចសន្យាលក់-ទិញដី ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងដើមបណ្តឹងតប និងចុងបណ្តឹងតប ។

២-ទទួលស្គាល់ដើមបណ្តឹងតប និងចុងបណ្តឹងតប បានអនុវត្តសិទ្ធិ និងកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យាលក់-ទិញដី ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ចប់ជាស្ថាពរ

៣-បង្គាប់ឱ្យចុងបណ្តឹងតបធ្វើនីតិវិធីផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី ឱ្យទៅដើមបណ្តឹងតបលើអចលនវត្ថុដីមានទំហំ៣១៤.៤៣៤ម² ដែលមានទីតាំងស្ថិតនៅភូមិព្រៃមូល និងភូមិព្រែក ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ។



Scanned with CamScanner

៤-បង្គាប់ឱ្យចុងបណ្តឹងតបប្រគល់អចលនវត្ថុទៅដើមបណ្តឹងតប និងចង្អុលបង្ហាញព្រំដី លើអចលនវត្ថុដីមានទំហំ ៣១៤.៤៣៤ម² មានទីតាំងស្ថិតនៅភូមិព្រៃមូល និងភូមិព្រែក ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ និងមានគំនូសបង្ហាញទីតាំងដីនៅឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

៥-បង្គាប់ឱ្យចុងបណ្តឹងតបឈ្មោះ[redacted] សុផល សងជំងឺចិត្ត សំណងការខូចខាត សំណងការខាតបង់ពេលវេលា និងសេវាមេធាវី សរុបចំនួន១០០.០០០$(ដប់ម៉ឺន)ដុល្លារអាមេរិក ឱ្យទៅដើមបណ្តឹងតប។

៦-ប្រកាសជាបណ្តោះអាសន្នត្រង់ចំនុចទី១,ទី២,ទី៣,ទី៤ និងទី៥ខាងលើនេះ ។

៧-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងបណ្តឹងតប ។

-ដើមចោទឈ្មោះ [redacted] សុផល ភេទ ប្រុស អាយុ ៤៣ ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ ទីលំនៅបច្ចុប្បន្ន [redacted]។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិការពារសិទ្ធិអោយដើមចោទ ឈ្មោះ [redacted] សុផល ។

-ចុងចម្លើយឈ្មោះ [redacted] ធារិទ្ធ ភេទប្រុស អាយុ ៥១ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ ទីលំនៅសព្វថ្ងៃនៅផ្ទះ [redacted]។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិការពារសិទ្ធិអោយចុងចម្លើយឈ្មោះ [redacted] ធារិទ្ធ

## អង្គហេតុ និងចំណុចវិវាទ៖

១-សាលក្រមដែលទាមទារដោយគូភាគី ៖

**១-១-ការទាមទារដោយដើមចោទ៖**

ក-សុំមោឃភាពកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដី) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងឈ្មោះ[redacted] ធារិទ្ធ និងឈ្មោះ[redacted] គឹមហេង ឈ្មោះ[redacted] សុផល ។

ខ-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

ពាក្យសុំកែតម្រូវពាក្យបណ្តឹងរបស់មេធាវីដើមចោទ៖

ក-សុំរំលាយកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដី) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងឈ្មោះ[redacted] ធារិទ្ធ និងឈ្មោះ[redacted] គឹមហេង ឈ្មោះ [redacted] សុផល (រំលាយឆន្ទៈរបស់ឈ្មោះកេង សុផល) ។

ខ-ទាមទារសំណងនៃការខូចខាតចំនួន១០.០០០$ (ដប់ពាន់)ដុល្លារ និងប្រាក់កក់ទាំងអស់ដែលកូនក្តីរបស់ខ្ញុំបានទទួលកន្លងមកពីភាគីអ្នកទិញ(ដី) ចាត់ទុកជាផលប្រយោជន៍របស់កូនក្តី ។

គ-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**១-២-ការទាមទារដោយចុងចម្លើយ៖**

១-ទទួលស្គាល់កិច្ចសន្យាលក់-ទិញដី ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងដើមបណ្តឹងតប និងចុងបណ្តឹងតប ។

២-ទទួលស្គាល់ដើមបណ្តឹងតប និងចុងបណ្តឹងតប បានអនុវត្តសិទ្ធិ និងកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យាលក់-ទិញដី ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ចប់ជាស្ថាពរ

៣-បង្គាប់ឱ្យចុងបណ្តឹងតបធ្វើនីតិវិធីផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី ឱ្យទៅដើមបណ្តឹងតបលើអចលនវត្ថុដីមានទំហំ៣១៤.៤៣៤ម² ដែលមានទីតាំងស្ថិតនៅភូមិព្រៃមូល និងភូមិព្រែក ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ។



Scanned with CamScanner

៤-បង្គាប់ឱ្យចុងបណ្តឹងតបប្រគល់អចលនវត្ថុទៅដើមបណ្តឹងតប និងចង្អុលបង្ហាញព្រំដី លើអចលនវត្ថុដីមានទំហំ ៣១៤.៤៣៤ម² មានទីតាំងស្ថិតនៅភូមិព្រៃមូល និងភូមិព្រែក ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ និងមានគំនូសបង្ហាញទីតាំងដីនៅឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

៥-បង្គាប់ឱ្យចុងបណ្តឹងតបឈ្មោះ[redacted] សុផល សងជំងឺចិត្ត សំណងការខូចខាត សំណងការខាតបង់ពេលវេលា និងសេវាមេធាវី សរុបចំនួន១០០.០០០$(ដប់ម៉ឺន)ដុល្លារអាមេរិក ឱ្យទៅដើមបណ្តឹងតប។

៦-ប្រកាសជាបណ្តោះអាសន្នត្រង់ចំនុចទី១,ទី២,ទី៣,ទី៤ និងទី៥ខាងលើនេះ ។

៧-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងបណ្តឹងតប ។

២-ការពន្យល់ត្រួសៗអំពីរឿងក្តី:

កាលពីថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០១៨ ឈ្មោះ[redacted] គីមហេង និងដើមចោទឈ្មោះ[redacted] សុផល បានលក់ដីទំហំ៣១៤.៤៣៤ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃមូលនិងភូមិព្រែក ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ អោយទៅឈ្មោះ[redacted] ធារិទ្ធ ក្នុងតម្លៃមួយម៉ែត្រការ៉េ១,៥០$(មួយក្បៀសហាសិប)ដុល្លារ ដោយបានធ្វើកិច្ចសន្យាត្រឹមត្រូវ ក្នុងនោះឈ្មោះ[redacted] សុផល មានដីទំហំ១៣ហិកតា ដោយបានធ្វើកិច្ចសន្យាប្រគល់-ទទួលប្រាក់ត្រឹមត្រូវ គឺដំណាក់កាលទី១ ២០% ស្មើចំនួន៦១.០០០$ ដើមចោទឈ្មោះកេង សុផលទទួលបានប្រាក់ចំនួន១៩.៦០០$ ហើយចុងចម្លើយឈ្មោះ[redacted] ធារិទ្ធ យល់ព្រមប្រគល់ប្រាក់ដំណាក់កាលទី២ចំនួន៣០%នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០១៨ និងត្រូវប្រគល់ប្រាក់ដំណាក់កាលទី៣ ៥០% ។ ប៉ុន្តែចុងចម្លើយឈ្មោះ[redacted] ធារិទ្ធ ពុំបានគោរពតាមកិច្ចសន្យាប្រគល់ប្រាក់លើកទី២ ៣០% និងលើកទី៣ ៥០% នោះទេ ។

៣-អង្គហេតុដែលមានវិវាទ:

តើដើមចោទសុំរំលាយកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដី) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងឈ្មោះ[redacted]ធារិទ្ធ និងឈ្មោះ[redacted] គីមហេង ឈ្មោះ [redacted] សុផល (រំលាយឆន្ទៈរបស់ឈ្មោះកេង សុផល) និងចុងចម្លើយសុំឱ្យទទួលស្គាល់កិច្ចសន្យាលក់-ទិញដី ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងដើមបណ្តឹងតប និងចុងបណ្តឹងតបមួយណាមានអាទិភាពជាង ?

៤-អង្គហេតុដែលគ្មានវិវាទ:គ្មាន

៥-សេចក្តីថ្លែងការណ៍របស់គូភាគី:

ក-សេចក្តីថ្លែងការណ៍របស់ដើមចោទ

-ដើមចោទឈ្មោះ [redacted] សុផល បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្ញុំបាទនៅតែប្តឹងសុំដូចកម្មវត្ថុខាងលើ ដោយសំអាងលើមូលហេតុ កាលពីថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០១៨ ឈ្មោះ វ៉ិល គីមហេង និងរូបខ្ញុំបាទបានលក់ដីទំហំ៣១៤.៤៣៤ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃមូលនិងភូមិព្រែក ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ អោយទៅឈ្មោះ[redacted] ធារិទ្ធ ក្នុងតម្លៃមួយម៉ែត្រការ៉េ១,៥០$(មួយក្បៀសហាសិប)ដុល្លារ ដោយបានធ្វើកិច្ចសន្យាត្រឹមត្រូវ ប៉ុន្តែដីខ្ញុំមានទំហំ១៣ហិកតា ហើយបានធ្វើកិច្ចសន្យាប្រគល់-ទទួលប្រាក់ត្រឹមត្រូវ គឺដំណាក់កាលទី១ ២០% ស្មើចំនួន៦១.០០០$ ខ្លួនទទួលបានប្រាក់ចំនួន១៩.៦០០$ និងយល់ព្រមប្រគល់ប្រាក់ដំណាក់កាលទី២ចំនួន៣០% នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៨ ហើយត្រូវប្រគល់ប្រាក់ដំណាក់កាលទី៣ ៥០%។ ប៉ុន្តែឈ្មោះ[redacted]ធារិទ្ធ ពុំបានគោរពតាមកិច្ចសន្យាប្រគល់ប្រាក់លើកទី២ ៣០% នោះទេ ចុងចម្លើយបានគេចវេសពីការប្រគល់ប្រាក់ទោះជាខ្ញុំបានទាក់ទងទាមទារប្រាក់ជាច្រើនលើក តែគាត់ឆ្លើយថាប្រគល់ថ្ងៃនេះ ថ្ងៃនេះរហូតមកដល់បច្ចុប្បន្ននេះ ។ ហេតុនេះទើបខ្ញុំប្តឹងសុំរំលាយកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដី) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងឈ្មោះ



Scanned with CamScanner

[redacted]ធារិទ្ធ និងឈ្មោះ[redacted] គីមហេង ឈ្មោះ [redacted] សុផល និងទាមទារយកប្រាក់កក់ចំនួន១៩.៦០០$ ដែលចុងចម្លើយបានកក់ប្រាក់ថ្លៃទិញដីខ្ញុំចំនួន១៣ហិកតា ។

-លោក [redacted] មេធាវីតំណាងដោអាណត្តិអោយដើមចោទបានថ្លែងការណ៍ថាកូនក្តីរបស់ខ្ញុំបាទបានទទួលប្រាក់កក់លើកទី១ចំនួន១៩.៦០០$ លើការលក់ដីចំនួន១៣ហិកតា ចំណែកដំណាក់កាលទី២ចំនួន៣០% នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៨ និងដំណាក់កាលទី៣ ៥០% កូនក្តីរបស់ខ្ញុំពុំបានទទួលប្រាក់នោះទេ ។ ម្យ៉ាងវិញទៀតដីនេះ កូនក្តីខ្ញុំពុំបានលក់ទៅអោយអ្នកណាទេ ។ ដោយចុងចម្លើយមិនគោរពតាមកិច្ចសន្យា ហេតុនេះសុំអោយតុលាការសម្រេចរំលាយកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដី) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងឈ្មោះ [redacted]ធារិទ្ធ និងឈ្មោះ[redacted] គីមហេង ឈ្មោះ [redacted]សុផល ។ និងសុំទាមទារប្រាក់កក់ ដែលកូនក្តីរបស់ខ្ញុំទទួលបានទុកជាអសារបង់ ព្រមទាំងទាមទារសំណងជំងឺចិត្ត សំណងការខូចខាត សំណងការខាតបង់ពេលវេលា សរុបចំនួន ១០.០០០$(ដប់ម៉ឺន)ដុល្លារអាមេរិក ឱ្យទៅដើមចោទ ។

ខ-សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ

-ចុងចម្លើយឈ្មោះ [redacted]ធារិទ្ធ អវត្តមាន

-លោក[redacted]មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើ បានចូលមកថ្លែងការណ៍ថា ពាក្យសុំកែតម្រូវពាក្យបណ្តឹងរបស់មេធាវីតំណាងដោយអាណត្តិអោយដើមចោទ បានដាក់ជូនតុលាការ មិនត្រឹមត្រូវតាមច្បាប់ ព្រោះដល់ពេលនីតិវិធីទាញហេតុផលទើបយកមកដាក់ ពុំបានជូនដំណឹងដល់កូនក្តីខ្ញុំឡើយ ហេតុនេះសុំបដិសេធនិងចោលទាំងស្រុង ។ ខ្ញុំសូមបញ្ជាក់ជូនថា កូនក្តី របស់ខ្ញុំឈ្មោះ[redacted]ធារិទ្ធ ពិតជាបានទិញដីរបស់ដើមចោទ និងបានធ្វើកិច្ចសន្យាចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ប្រាកដមែន ។ នៅក្នុងរឿងនេះកូនក្តីរបស់បានធ្វើបណ្តឹងតបសុំឱ្យតុលាការសម្រេចៈច្រានចោលពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ១-ទទួលស្គាល់កិច្ចសន្យាលក់-ទិញដី ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងដើមបណ្តឹងតប និងចុងបណ្តឹងតប ។ ២-ទទួលស្គាល់ដើមបណ្តឹងតប និងចុងបណ្តឹងតប បានអនុវត្តសិទ្ធិ និងកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យាលក់-ទិញដី ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ចប់ជាស្ថាពរ ។ ៣-បង្គាប់ឱ្យចុងបណ្តឹងតបធ្វើនីតិវិធីផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យមិនទាន់ចុះបញ្ជី ឱ្យទៅដើម បណ្តឹងតបលើអចលនវត្ថុដីមានទំហំ ៣១៤.៤៣៤ម$^{2}$ ដែលមានទីតាំងស្ថិតនៅភូមិព្រៃមូល និងភូមិព្រែក ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ។ ៤-បង្គាប់ឱ្យចុងបណ្តឹងតបប្រគល់អចលនវត្ថុទៅដើមបណ្តឹងតប និងចង្អុលបង្ហាញព្រំដី លើអចលនវត្ថុដីមានទំហំ ៣១៤.៤៣៤ម$^{2}$ មានទីតាំងស្ថិតនៅភូមិព្រៃមូល និងភូមិព្រែក ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ និងមានគំនូសបង្ហាញទីតាំងដីនៅឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ។ ៥-បង្គាប់ឱ្យចុងបណ្តឹងតបឈ្មោះកេង សុផល សងជំងឺចិត្ត សំណងការខូចខាត សំណងការខាតបង់ពេលវេលា និងសេវាមេធាវី សរុបចំនួន ១០០.០០០$(ដប់ម៉ឺន)ដុល្លារអាមេរិក ឱ្យទៅដើមបណ្តឹងតប ។ ៦-ប្រកាសជាបណ្តោះអាសន្នត្រង់ចំនុចទី១,ទី២, ទី៣,ទី៤ និងទី៥ខាងលើនេះ ។ ៧-ប្រាក់ប្រដាប់ក្តីជាបន្ទុកជាបន្ទុករបស់ចុងបណ្តឹងតប ដោយសំអាងហេតុថាកាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ដើមចោទបានចុះកិច្ចសន្យាលក់-ទិញដី ទំហំ៣១៤.៤៣៤ម$^{2}$ ជាមួយកូនក្តីរបស់ខ្ញុំបាទឈ្មោះ[redacted] ធារិទ្ធ ហើយកូនក្តីខ្ញុំបានទូទាត់ប្រាក់គ្រប់ចំនួនអោយទៅដើមចោទតាមដំណាក់កាលហើយ ចុងបណ្តឹងតបអាចធ្វើលិខិតលក់-ទិញផ្តាច់ និងលិខិតកាន់កាប់ប្រើប្រាស់ដីធ្លី ទៅឱ្យអ្នកទិញបន្តពីដើមបណ្តឹងតប ដោយផ្ទាល់បាន ។ ក្រោយពីបានទូទាត់ប្រាក់ទៅឱ្យឈ្មោះ[redacted] គីមហេង និងឈ្មោះ[redacted] សុផល រួចចុងបណ្តឹងតបបានធ្វើលិខិតលក់ផ្តាច់ទៅឱ្យឈ្មោះ[redacted] ហុង (អ្នកទិញបន្តពីដើមបណ្តឹងតប) ផ្ទាល់តែម្តងបាន ។ ចំពោះលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចុងបណ្តឹងតបបានឆ្លើយយកលេសថា ភូមិ-ឃុំ ពុំទាន់បានធ្វើរួចរាល់



Scanned with CamScanner

សុំអោយរងចាំបន្តិច ។ ចាប់ពីពេលនោះមកដើមចោទពុំបានប្រគល់លិខិតកាន់កាប់ដីធ្លីអោយកូនក្តីខ្ញុំឡើយ ។ ក្រោយមកកូនក្តីរបស់ខ្ញុំបានសុំណាត់ជួបចុងបណ្តឹងតបជាច្រើនលើក ប៉ុន្តែចុងបណ្តឹងតបគេចវេសមិនព្រមប្រគល់អោយឡើយ ដោយឆ្លើយដោះសារទៅអាជ្ញាធរមិនទាន់ចុះតហ្ថលេខាអោយ ។ ហេតុនេះទើបកូនក្តីរបស់ខ្ញុំដាក់បណ្តឹងតបទាមទារដូចក្នុងបណ្តឹងតបចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ។ សុំអោយលោកចៅក្រមសម្រេចអោយកូនក្តីខ្ញុំដោយក្តីអនុគ្រោះ ។

-លោក[redacted]ជាមេធាវីតំណាងដោយអាណត្តិអោយដើមចោទឈ្មោះ[redacted] សុផល បានថ្លែងការណ៍ថា យើងប្តឹងផ្តល់គ្នារឿងពាក់ព័ន្ធរំលាយកិច្ចសន្យា ប៉ុន្តែលោកមេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយលើកឡើងពីអង្គហេតុផ្សេង ដោយថាកូនក្តីខ្ញុំសុខចិត្តលក់ដីនេះបន្តអោយឈ្មោះ[redacted] ហុង មិនស្របតាមមាត្រា ៤០៧,៤០៨ នៃក្រមរដ្ឋប្បវេណី មិនគោរពតាមកាតព្វកិច្ចប្តឹងសុំ សុំអោយតុលាការរំលាយកិច្ចសន្យា ។ ហេតុនេះសុំច្រានចោលអង្គហេតុដែលថាកូនក្តីខ្ញុំព្រមលក់ដីនេះបន្តអោយតតីយជន ។ អង្គហេតុដែលជាអង្គហេតុវិវាទ គឺជាចុងចម្លើយ បានប្រគល់ប្រាក់គ្រប់ចំនួនតាមកិច្ចសន្យា ឬអត់?។ ចំពោះអង្គហេតុលើបណ្តឹងតបរបស់ចុងចម្លើយយកភស្តុតាងថាកូនក្តីខ្ញុំលក់ដីផ្តាច់អោយទៅតតីយជន មកធ្វើជាការប្រគល់លុយគ្រប់ចំនួនតាមកិច្ចសន្យាដែលខ្ញុំសុំរំលាយនេះ មិនត្រូវទេ ភស្តុតាងថាបានប្រគល់ប្រាក់គឺលិខិតប្រគល់-ទទួលប្រាក់ ដែលមានធ្វើដូចក្នុងដំណាក់កាលទី១ ។ ហេតុនេះខ្ញុំប្តឹងសុំរំលាយកិច្ចសន្យា និងទាមទារជំងឺចិត្ត ដូចមាននៅក្នុងសេចក្តីថ្លែងការណ៍ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៤ ដែលបានដាក់ជូនតុលាការស្រាប់ ។

-ដើមចោទឈ្មោះ [redacted] សុផល បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្ញុំបាទពិតជាបានផ្តិតមេដៃលើក្រដាសសមួយសន្លឹកអោយទៅឈ្មោះ[redacted] ធារិទ្ធ ដោយគាត់ប្រាប់ថាថ្ងៃស្អែកគាត់និងប្រគល់ប្រាក់គ្រប់ចំនួន ។ តែចាប់ពីពេលនោះមកឈ្មោះ[redacted] ធារិទ្ធ ពុំបានគោរពតាមកិច្ចសន្យា ខ្ញុំបាទតាមទារគាត់ឆ្លើយដោះសារថ្ងៃនេះថ្ងៃនោះ ម្តងថានៅខេត្តព្រះសីហនុ ម្តងថានៅវាលវែង ពុំព្រមជួបខ្ញុំឡើយ ។

-លោកមេធាវី [redacted] បានចូលមកថ្លែងការណ៍ថា កូនក្តីរបស់ខ្ញុំបានប្រគល់ប្រាក់គ្រប់ចំនួនរួចហើយទើប ដើមចោទសុខចិត្តផ្តិតមេដៃលើលិខិតលក់ទិញបន្ត ព្រោះកុំអោយខាតបង់ក្នុងការកាត់ផ្ទេរឈ្មោះប្លង់ដី ។ ហេតុនេះសុំអោយតុលាការសម្រេចតាមពាក្យបណ្តឹងតបរបស់កូនក្តីរបស់ខ្ញុំបាទ ។

៦-ការពិនិត្យភស្តុតាងមានៈ

ក-ភស្តុតាងជាសាក្សី

-សាក្សីឈ្មោះម្សៀច រី បានចូលមកឆ្លើយថា ខ្ញុំបាទត្រូវជាមេភូមិព្រែក ឃុំចំប៉ី នៅថ្ងៃខែមិនចាំ ខ្ញុំបាទបានចុះហត្ថលេខាលើលិខិតមួយច្បាប់ដែលឈ្មោះកេង ត្រូវជាឪពុករបស់ឈ្មោះ[redacted] សុផល យកមកអោយខ្ញុំចុះហត្ថលេខា ពេលនោះខ្ញុំឃើញនៅក្នុងលិខិតមានស្នាមមេដៃអ្នកលក់ដីឈ្មោះ[redacted] សុផល ចំណែកអ្នកទិញ មិនទាន់មានឈ្មោះនិងស្នាមមេដៃទេ ។ ខ្ញុំហ៊ានចុះហត្ថលេខាដោយសារឈ្មោះកេង ជាអ្នកកាន់យកមក ។

-សាក្សីឈ្មោះ[redacted] ចយ បានចូលមកឆ្លើយថា ខ្ញុំបាទបានចុះហត្ថលេខាលើលិខិតលក់ ទិញដីមួយច្បាប់ដែលឈ្មោះកេង ត្រូវជាឪពុករបស់ឈ្មោះ[redacted] សុផល មកអោយខ្ញុំចុះហត្ថលេខា ពេលនោះខ្ញុំឃើញលោកមេភូមិបានចុះហត្ថលេខារួចហើយ នៅក្នុងលិខិតមានស្នាមមេដៃអ្នកលក់ដីឈ្មោះ[redacted] សុផល ចំណែកអ្នកទិញ មិនទាន់មានឈ្មោះនិងស្នាមមេដៃទេ ។ មុនចុះហត្ថលេខាខ្ញុំបានសួរសៀនដែរ ព្រោះពេលនោះខ្ញុំទើបឡើងធ្វើជាមេឃុំរយៈពេល២ខែប៉ុណ្ណោះ ខ្ញុំហ៊ានចុះហត្ថលេខាដោយសារឈ្មោះកេង ត្រូវជាឪពុក[redacted] សុផល កាន់យកមកទើបខ្ញុំចុះហត្ថលេខា អោយ ។

ខ-ភស្តុតាងជាលិខិតស្នាម

-ពាក្យបណ្ដឹង ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] សុផល

-កិច្ចសន្យាទិញ-លក់អចលនវត្ថុ(ដី) រវាងលោក [redacted] ធារិទ្ធ(ជាអ្នកទិញហៅភាគីក)និងលោក [redacted] គីមហេង លោក [redacted] សុផល(ជាអ្នកលក់ ហៅភាគីខ) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

-លិខិតប្រគល់-ទទួលប្រាក់កក់ថ្លៃដី ដំណាក់កាលទី១ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨

-កិច្ចសន្យាលក់ផ្ដាច់ អ្នកលក់ឈ្មោះ [redacted] លាងហៃ អ្នកទិញឈ្មោះ [redacted] សុផលចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០១៨ ។

-លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី អ្នកផ្ទេរសិទ្ធិឈ្មោះ [redacted] លាងហៃ អ្នកទទួលសិទ្ធិឈ្មោះ [redacted] សុផលចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៨ ។

-កិច្ចសន្យាលក់ផ្ដាច់ អ្នកលក់ឈ្មោះវិល គីមហេង និងឈ្មោះ [redacted] សុផល អ្នកទិញឈ្មោះ [redacted] ហុង ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ។

-ពាក្យសុំកែតម្រូវពាក្យបណ្ដឹងចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ របស់លោក [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិអោយដើមចោទឈ្មោះកេង សុផល ។

-សេចក្ដីថ្លែងការណ៍របស់មេធាវី [redacted] ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់ឈ្មោះ [redacted] សុផល

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់ឈ្មោះ [redacted] គីមហេង

## **សំអាងហេតុ**

**១**-បណ្ដឹងរបស់ដើមចោទឈ្មោះ [redacted] សុផល ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ មានលក្ខណៈត្រឹមត្រូវតាមទំរង់ តែពុំស្របនិងគតិច្បាប់ ហើយលោកមេធាវីតំណាងដោយអាណត្តិអោយដើមចោទ បានដាក់ពាក្យសុំកែតម្រូវពាក្យបណ្ដឹង ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ សុំកែតម្រូវពាក្យបណ្ដឹងរបស់ដើមចោទចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ក-សុំរំលាយកិច្ចសន្យាទិញ-លក់អចលនវត្ថុ(ដី) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងឈ្មោះ [redacted] ធារិទ្ធ(ជាអ្នកទិញហៅភាគីក) និងឈ្មោះ [redacted] គីមហេង ឈ្មោះ [redacted] សុផល (រំលាយឆន្ទៈរបស់ឈ្មោះ [redacted] សុផល) ។ ខ-សុំទាមទារសំណងនៃការខូចខាតចំនួន១០.០០០$ និងប្រាក់កក់ទាំងអស់ដែលកូនក្ដីខ្ញុំបាទបានទទួលកន្លងមកពីភាគីអ្នកទិញដី ចាត់ទុកជាផលប្រយោជន៍របស់កូនក្ដីខ្ញុំបាទ ។ គ-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។ តុលាការគប្បីទទួលមកចាត់ការត្រង់ចំណុច(ក) ចំណែកចំណុច(ខ)និងចំណុច(គ) តុលាការពុំលើកយកមកពិចារណាឡើយ ព្រោះដល់ពេលទាញហេតុផលទើបលោកមេធាវីដាក់ពាក្យសុំកែតម្រូវចូលមកតុលាការ ។

**២**-ដើមចោទឈ្មោះ [redacted] សុផល ប្ដឹងសុំរំលាយកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដី) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងឈ្មោះ [redacted] ធារិទ្ធ និងឈ្មោះវិល គីមហេង ឈ្មោះ [redacted] សុផល ដោយសំអាងហេតុថា កាលពីថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០១៨ ឈ្មោះ [redacted] គីមហេង និងរូបខ្ញុំបាទបានលក់ដីទំហំ៣១៤.៤៣៤ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃមូលនិងភូមិព្រែក ឃុំចុំពុំ ស្រុកបាទី ខេត្តតាកែវ អោយទៅឈ្មោះ [redacted] ធារិទ្ធ ក្នុងតម្លៃមួយម៉ែត្រការ៉េ១,៩០$(មួយក្បៀសហាសិប)ដុល្លារ ដោយបានធ្វើកិច្ចសន្យាត្រឹមត្រូវ ប៉ុន្តែដីខ្លួនមានតែទំហំ១៣ហិកតា ហើយបានធ្វើកិច្ចសន្យាប្រគល់-ទទួលប្រាក់ត្រឹមត្រូវ គឺដំណាក់កាលទី១ ២០% ស្មើចំនួន៦១.០០០$ ខ្លួនទទួលបានប្រាក់ចំនួន១៩.៦០០$ និងយល់ព្រមប្រគល់ប្រាក់ដំណាក់កាលទី២ចំនួន៣០%នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ



Scanned with CamScanner

២០១៨ ហើយត្រូវប្រគល់ប្រាក់ដំណាក់កាលទី៣ ៥០% ។ ប៉ុន្តែឈ្មោះ[redacted]ធារិទ្ធ ពុំបានគោរពតាមកិច្ចសន្យាប្រគល់ប្រាក់លើកទី២ ៣០% នោះទេ ចុងចម្លើយបានគេចវេសពីការប្រគល់ប្រាក់ទោះជាខ្លួនបានទាក់ទងទាមទារប្រាក់ជាច្រើនលើក តែគាត់ឆ្លើយថាំប្រគល់ថ្ងៃនេះ ថ្ងៃនេះរហូតមកដល់បច្ចុប្បន្ននេះ ។ ការលើកឡើងនេះ តុលាការទទួលយកមកពិនិត្យពិចារណា និងសម្រេចតាមច្បាប់ ។

៣-ដើមចោទឈ្មោះ[redacted] សុផល បានថ្លែងការណ៍ថាខ្លួនប្តឹងសុំរំលាយកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដី) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងឈ្មោះ [redacted]ធារិទ្ធ និងឈ្មោះ[redacted]គីមហេង ឈ្មោះ [redacted] សុផល តែចំណែកដីរបស់ខ្លួនមានចំនួន១៣ហិកតា ប៉ុណ្ណោះ ដោយសារចុងចម្លើយឈ្មោះ[redacted]ធារិទ្ធ ពុំព្រមគោរពតាមកិច្ចសន្យា ។ តុលាការគប្បីពិនិត្យពិចារណា និងសម្រេច ផ្អែកលើភស្តុតាងដែលបានដាក់ជូនតុលាការ ។

៤-តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិអោយដើមចោទថា: ប្តឹងសុំកែតម្រូវពាក្យបណ្តឹង ១-សុំរំលាយកិច្ចសន្យាទិញ-លក់អចលនវត្ថុ(ដី) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងឈ្មោះ[redacted] ធារិទ្ធ(ជាអ្នកទិញហៅភាគីក) និងឈ្មោះ[redacted]គីមហេង ឈ្មោះ[redacted]សុផល (រំលាយឆន្ទៈរបស់ឈ្មោះ[redacted] សុផល) ។ ២-សុំទាមទារសំណងនៃការខូចខាតចំនួន១០.០០០$ និងប្រាក់កក់ទាំងអស់ដែលកូនក្តីខ្ញុំបាទបានទទួលកន្លងមកពីភាគីអ្នកទិញដី ចាត់ទុកជាផលប្រយោជន៍របស់កូនក្តីខ្ញុំបាទ ។ តុលាការគប្បីទទួលមកចាត់ការត្រង់ចំណុចក ចំណែកចំណុចខ និងគ តុលាការពុំលើកយកមកពិចាណារឡើយ ព្រោះដល់ពេលទាញហេតុផលទើបលោកមេធាវីដាក់ពាក្យសុំកែតម្រូវចូលមកតុលាការ ។

៥-តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយថា:ចុងចម្លើយបានដាក់បណ្តឹងតប ១-ទទួលស្គាល់កិច្ចសន្យាលក់-ទិញដី ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងដើមបណ្តឹងតប និងចុងបណ្តឹងតប ។ ២-ទទួលស្គាល់ដើមបណ្តឹងតប និងចុងបណ្តឹងតប បានអនុវត្តសិទ្ធិ និងកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យាលក់-ទិញដី ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ចប់ជាស្ថាពរ ។ ៣-បង្គាប់ឱ្យចុងបណ្តឹងតបធ្វើនីតិវិធីផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី ឱ្យទៅដើមបណ្តឹងតបលើអចលនវត្ថុដីមានទំហំ៣១៤.៤៣៤ម$^{២}$ ដែលមានទីតាំងស្ថិតនៅភូមិព្រៃមូល និងភូមិព្រែក ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ។ ៤-បង្គាប់ឱ្យចុងបណ្តឹងតបប្រគល់អចលនវត្ថុទៅដើមបណ្តឹងតប និងចង្អុលបង្ហាញព្រំដី លើអចលនវត្ថុដីមានទំហំ ៣១៤.៤៣៤ម$^{២}$ មានទីតាំងស្ថិតនៅភូមិព្រៃមូល និងភូមិព្រែក ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ និងមានគំនូសបង្ហាញទីតាំងដីនៅឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ។ ៥-បង្គាប់ឱ្យចុងបណ្តឹងតបឈ្មោះ[redacted] សុផល សងជំងឺចិត្ត សំណងការខូចខាត សំណងការខាតបង់ពេលវេលា និងសេវាមេធាវីសរុបចំនួន១០០.០០០$(ដប់ម៉ឺន)ដុល្លារអាមេរិក ឱ្យទៅដើមបណ្តឹងតប ។ ៦-ប្រកាសជាបណ្តោះអាសន្នត្រង់ចំនុចទី១,ទី២,ទី៣,ទី៤ និងទី៥ខាងលើនេះ ។ ៧-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងបណ្តឹងតប ដោយសំអាងហេតុថា: កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ដើមចោទបានចុះកិច្ចសន្យាលក់-ទិញដី ទំហំ៣១៤.៤៣៤ម$^{២}$ ជាមួយកូនក្តីរបស់ខ្ញុំបាទឈ្មោះ[redacted] ធារិទ្ធ ហើយកូនក្តីខ្ញុំបានទូទាត់ប្រាក់គ្រប់ចំនួនអោយទៅដើមចោទតាមដំណាក់កាលរួចហើយ ។ ការលើកឡើងរបស់មេធាវី តុលាការពិនិត្យឃើញថាចំណុចទី១កិច្ចសន្យាទិញ-លក់ដី ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ចំណែកចំណុចទី២,៣,៤,៥និងទី៦ តុលាការពិនិត្យពិចារណា និងសម្រេចតាមភស្តុតាង ។

៦-តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយថា: កូនក្តីរបស់ខ្លួនបានព្រមព្រៀងជាមួយដើមចោទដោយផ្ទាល់មាត់ថា អាចយកដីនេះទៅលក់បន្តបាន ដើម្បីកុំអោយខាតបង់ក្នុងការកាត់



Scanned with CamScanner

ឈ្មោះ ។ ហេតុនេះទើបឱ្យឈ្មោះ[redacted] គីមហេង និងឈ្មោះ[redacted] សុផល ធ្វើលិខិតលក់ផ្តាច់ទៅឱ្យឈ្មោះ[redacted] ហុង អ្នកទិញផ្ទាល់តែម្តង ។ គប្បីតុលាការពិនិត្យពិចារណា និងសម្រេចតាមច្បាប់ ។

៧-បើពិនិត្យទៅលើសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយថា កូនក្តីរបស់ខ្លួនឈ្មោះ[redacted] ធារិទ្ធ បានទូទាត់ប្រាក់គ្រប់ដំណាក់កាលទៅអោយដើមចោទរួចរាល់ ហើយដើមចោទមិនទាន់ធ្វើការផ្ទេរឈ្មោះប្លង់ដីមកអោយកូនក្តីខ្លួន ។ ហេតុនេះសុំអោយដើមចោទធ្វើនីតិវិធីផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី ឱ្យទៅដើមបណ្តឹងតបលើអចលនវត្ថុដីមានទំហំ៣១៤.៤៣៤ម$^{២}$ ដែលមានទីតាំងស្ថិតនៅភូមិព្រៃមូល និងភូមិព្រែក ឃុំចំប៊ី ស្រុកបាទី ខេត្តតាកែវ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ។ ការលើកឡើងនេះពុំមានភស្តុតាង ឬលិខិតស្នាមប្រគល់-ទទួលប្រាក់តាមដំណាក់កាល ដាក់ជូនតុលាការពិនិត្យពិចារណានិងសម្រេចឡើយ ។

៨-តាមសេចក្តីថ្លែងការណ៍របស់ដើមចោទថា: ពិតជាបានផ្តិតមេដៃលើក្រដាសសមួយសន្លឹកប្រាកដមែន ។ ខ្លួនផ្តិតនេះដើម្បីទុកសម្រាប់ទូទាត់ប្រាក់ពេលក្រោយ ពុំមែនយល់ព្រមផ្តិតមេដៃលក់បន្តទៅអោយអ្នកផ្សេងទេ ហើយខ្លួនក៏បានឃើញលិខិតមួយច្បាប់ដែលអាជ្ញាធរភូមិ ឃុំ ចុះហត្ថលេខា បញ្ជាក់ថាខ្លួនលក់ដីនេះទៅអោយឈ្មោះ[redacted] ហុង ។ ខ្លួនសុំបដិសេធន៍លិខិតលក់ទិញដីនេះចោល ។ ការលើកឡើងរបស់ដើមចោទមានភាពស៊ីសង្វាក់គ្នាជាមួយចម្លើយសាក្សីបំភ្លឺឈ្មោះ[redacted] រី និងឈ្មោះ[redacted] ចយ ជាអាជ្ញាធរភូមិ ឃុំ ។ គប្បីតុលាការពិនិត្យពិចារណាសម្រេចតាមច្បាប់ ។

៩-តាមចម្លើយសាក្សីបំភ្លឺឈ្មោះ[redacted] រី និងឈ្មោះ[redacted] ចយ មានខ្លឹមសារប្រហាក់ប្រហែលគ្នាថាខ្លួនជាមេភូមិព្រែក និងជាមេឃុំចំប៊ី នៅថ្ងៃខែមិនចាំ ខ្លួនបានចុះហត្ថលេខាលើលិខិតមួយច្បាប់ដែលឈ្មោះកេង ត្រូវជាឪពុករបស់ឈ្មោះ[redacted] សុផល យកមកអោយខ្លួនចុះហត្ថលេខាពេលនោះខ្លួនឃើញនៅក្នុងលិខិតមានស្នាមមេដៃអ្នកលក់ដីឈ្មោះ[redacted] សុផល ចំណែកអ្នកទិញ មិនទាន់មានឈ្មោះនិងស្នាមមេដៃទេ ។ ខ្ញុំហ៊ានចុះហត្ថលេខាដោយសារឈ្មោះកេង ជាអ្នកកាន់យកមក ។ តុលាការគប្បីពិនិត្យពិចារណា និងសម្រេចតាមសភាពជាក់ស្តែង ។

១០-តាមកិច្ចសន្យាទិញ-លក់អចលនវត្ថុ(ដី) រវាងលោក[redacted] ធារិទ្ធ (ជាអ្នកទិញហៅភាគីក)និងលោក[redacted] គីមហេង លោក[redacted] សុផល(ជាអ្នកលក់ ហៅភាគីខ) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ បញ្ជាក់ថាឈ្មោះ[redacted] ធារិទ្ធ ជាអ្នកទិញដីហៅភាគី(ក) ឈ្មោះ[redacted] គីមហេង និងឈ្មោះ[redacted] សុផល ជាអ្នកលក់ដីហៅភាគី(ខ) ។ ភាគី(ខ)ជាម្ចាស់អចលនវត្ថុឬហៅកាត់ថាដីទំហំចំនួន៣១៤.៤៣៤ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិព្រៃមូល និងភូមិព្រែក ឃុំចំប៊ី ស្រុកបាទី ខេត្តតាកែវ មានគំនូសបង្ហាញទីតាំងដីនៅឃុំចំប៊ី ស្រុកបាទី ខេត្តតាកែវ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ។ ភាគី(ខ)បានលក់ដីទំហំនិងទីតាំងខាងលើឱ្យទៅភាគី(ក)ឯភាគី(ក)យល់ព្រមទិញដីខាងលើនេះពីភាគី(ខ)ដែរ ដោយបានព្រមព្រៀងគ្នាក្នុងតម្លៃ១,៥០$/ម$^{២}$ (មួយដុល្លារប្រាំកាក់ដុល្លារអាមេរិក) ។ ភាគី(ក)បានប្រគល់ប្រាក់កក់ចំនួន៦១.០០០$ (ប្រាំមួយម៉ឺនមួយពាន់ដុល្លារអាមេរិក) ។ គូភាគីបានព្រមព្រៀងគ្នា ភាគី(ក)យល់ព្រមប្រគល់ប្រាក់ថ្លៃទិញដីទៅឱ្យភាគី(ខ)៣០% ចំនួន១៤១.៤៥៥,៣$ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៨ និងភាគី(ក)យល់ព្រមប្រគល់ប្រាក់បង្គ្រប់ថ្លៃដីទៅឱ្យភាគី(ខ)ចំនួន៥០% មានប្រាក់ចំនួន២៣៥.៨២៥,៥$ ក្រោយការវាស់វែងដោយមន្ត្រីជំនាញសុរិយោដីនិងតាមយាមការសុរិយោដី និងនៅក្រោយពេលភាគី(ខ)រៀបចំបែបបទកាត់ឈ្មោះផ្ទេរកម្មសិទ្ធិលើដីដែលជាកម្មវត្ថុនៃការទិញ-លក់ត្រឹមតាមអាជ្ញាធរភូមិ-ឃុំរួចធ្វើការថតចម្លង



Scanned with CamScanner

ឯកសារដែលបានកាត់ឈ្មោះផ្ទេរកម្មសិទ្ធិរួចនោះឱ្យមកភាគី(ក) ដើម្បីធ្វើការត្រួតពិនិត្យក្នុងរយៈពេល១៥ថ្ងៃ ។ ក្រោយពីភាគី(ក)បានពិនិត្យឃើញថា បានកាត់ឈ្មោះផ្ទេរកម្មសិទ្ធិលើដីមកឱ្យភាគី(ក) ត្រឹមត្រូវតាមនីតិវិធីច្បាប់ ។ បន្ទាប់ពីភាគី(ខ) បានទទួលប្រាក់គ្រប់ចំនួនហើយភាគី(ខ)ត្រូវប្រគល់ច្បាប់ដើម នៃលិខិតផ្ទេរកម្មសិទ្ធិ ដែលបានដាក់ឈ្មោះភាគី(ក)រួច អោយទៅភាគី(ក)ដើម្បីបញ្ចប់កាតព្វកិច្ចនៃការទិញលក់ ។ តាមប្រការ៤ នៃកិច្ចសន្យាចែងពីកំហុស និងការពិន័យ៖ ក្នុងករណីភាគី(ក)កែប្រែឈប់ទិញដីខាងលើពីភាគី(ខ) ឬមិនបានបង់ប្រាក់ឱ្យបានគ្រប់ចំនួនជូនភាគី(ខ) ភាគី(ខ)មានសិទ្ធិរំលាយកិច្ចព្រមព្រៀងនេះ ហើយប្រាក់ដែលភាគី(ក)បានបង់ទៅឱ្យភាគី(ខ)ទាំងអស់ត្រូវទុកជាប្រយោជន៍របស់ភាគី(ខ)ដោយគ្មានការតវ៉ា ។ បើពិនិត្យទៅលើចម្លើយរបស់របស់ដើមចោទ និងឯកសារដែលគូភាគីដាក់ជូនតុលាការ ឃើញថាចុងចម្លើយបានបង់ប្រាក់កក់រួច ពុំបានបង់ប្រាក់៣០% និង៥០% តាមការកំណត់ដូចមានចែងនៅក្នុងកិច្ចសន្យានោះទេ ។ គប្បីតុលាការពិនិត្យពិចារណា និងសម្រេចផ្អែកតាមភស្តុតាង ដែលបានដាក់ជូនតុលាការ ។

១១-តាមលិខិតប្រគល់-ទទួលប្រាក់កក់ថ្លៃដី ដំណាក់កាលទី១ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ បញ្ជាក់ថា ឈ្មោះ[redacted]គីហេង និងឈ្មោះ[redacted]សុផល ជាអ្នកលក់ដីហៅថាភាគី(ខ) បានទទួលប្រាក់កក់ថ្លៃដីដំណាក់កាលទី១ចំនួន៦១.០០០$ លើដីទំហំ៣១៤.៤៣៤ម៉ែត្រការ៉េ ពីឈ្មោះ[redacted]ធារិទ្ធ ជាអ្នកទិញដី ហៅថាភាគី(ក) ដោយបានផ្តិតមេដៃ មានសាក្សី និងអាជ្ញាធរដឹងឮត្រឹមត្រូវ ។

១២-តាមចម្លើយដើមចោទឈ្មោះ[redacted] សុផល បញ្ជាក់ថាដីទំហំចំនួន៣១៤.៤៣៤ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិព្រៃមូល និងភូមិព្រែក ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ ក្នុងនោះដីរបស់ខ្លួនមានតែទំហំចំនួន១៣ហិកតា និងបានទទួលប្រាក់កក់ចំនួន១៩.៦០០$ ។ ហើយខ្លួនប្តឹងសុំរលាយកិច្ចសន្យាលើចំណែកដីរបស់ខ្លួនតែប៉ុណ្ណោះ ។ គប្បីតុលាការពិនិត្យពិចារណា និងសម្រេចតាមសភាពជាក់ស្តែង ។

១៣-តាមចម្លើយដើមចោទ មេធាវី និងមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ និងសាក្សី ព្រមទាំងភស្តុតាងនានា បញ្ជាក់បានថា កាលពីថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០១៨ ឈ្មោះ[redacted] គីមហេង និងឈ្មោះ[redacted] សុផល បានលក់ដីទំហំ៣១៤.៤៣៤ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃមូលនិងភូមិព្រែក ឃុំចុំប៉ី ស្រុកបាទី ខេត្តតាកែវ អោយទៅឈ្មោះ[redacted]ធារិទ្ធ ក្នុងតម្លៃមួយម៉ែត្រការ៉េ១,៥០$(មួយដុល្លារប្រាំកាក់)ដុល្លារអាមេរិក ប៉ុន្តែដីដើមចោទឈ្មោះ[redacted]សុផល មានទំហំ១៣ហិកតា ។ ក្នុងការលក់-ទិញដីនេះបានធ្វើកិច្ចសន្យាត្រឹមត្រូវ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយបានប្រគល់ប្រាក់តាមដំណាក់កាល គឺដំណាក់កាលទី១ ២០% ស្មើចំនួន៦១.០០០$ ដើមចោទទទួលបានប្រាក់ចំនួន១៩.៦០០$ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ជាប្រាក់កក់ និងយល់ព្រមប្រគល់ប្រាក់ដំណាក់កាលទី២ចំនួន៣០%នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៨ ហើយត្រូវប្រគល់ប្រាក់ដំណាក់កាលទី៣ ៥០% នៅពេលកាត់ឈ្មោះផ្ទេរកម្មសិទ្ធិរួច ។ ដើមចោទអះអាងថា ចុងចម្លើយឈ្មោះ[redacted] ធារិទ្ធ ពុំបានគោរពតាមកិច្ចសន្យាប្រគល់ប្រាក់លើកទី២ ៣០% និងលើកទី៣ ៥០% នោះទេ ចំណែកលោកមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានលើកឡើងថា កូនក្តីរបស់ខ្លួនបានប្រគល់ប្រាក់គ្រប់ចំនួនតាមដំណាក់កាលរួចហើយ ។ បើពិនិត្យទៅលើភស្តុតាងដែលដាក់ជូនតុលាការមានកិច្ចសន្យាទិញ-លក់អចលនវត្ថុ(ដី)ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ និងលិខិតប្រគល់-ទទួលប្រាក់កក់ថ្លៃដីដំណាក់កាលទី១ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ តែប៉ុណ្ណោះ ។ ហេតុនេះគប្បីតុលាការសម្រេចរំលាយកិច្ចសន្យាចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងអ្នកលក់ឈ្មោះ[redacted]សុផល និងអ្នកទិញឈ្មោះ[redacted]ធារិទ្ធ ស្របតាមប្រការ៤ នៃកិច្ចសន្យា និងមាត្រា៤០៧ មាត្រា៤០៨ នៃក្រមរដ្ឋប្បវេណី ។



Scanned with CamScanner

១៤-តាមកិច្ចសន្យាទិញ-លក់អចលនវត្ថុ(ដី) រវាងលោក[redacted]ធារិទ្ធ (ជាអ្នកទិញហៅភាគីក)និងលោក [redacted] គីមហេង លោក[redacted] សុផល(ជាអ្នកលក់ ហៅភាគីខ) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ប្រការ៤៖កំហុស និងពិន័យ ចំណុច៤.១ ចែងថា ក្នុងករណីភាគី(ក) កែប្រែឈប់ទិញដីខាងលើពីភាគី(ខ) ឬមិនបានបង់ប្រាក់ឱ្យបានគ្រប់ចំនួនជូនភាគី(ខ) ទៅតាមប្រការ២ ខាងលើនេះទេ ភាគី(ខ) មានសិទ្ធិរំលាយកិច្ចព្រមព្រៀងនេះ ហើយប្រាក់ដែលភាគី(ក) បានបង់ទៅឱ្យភាគី(ខ) ទាំងអស់ត្រូវទុកជាប្រយោជន៍របស់ភាគី(ខ) ដោយគ្មានការតវ៉ា ។

១៥-ប្រាក់ប្រដាប់ក្តី គប្បីតុលាការអនុវត្តតាមមាត្រា ៦៤ កឋាខណ្ឌ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺជាបន្ទុករបស់ដើមចោទ ។

## សេចក្តីសម្រេចបញ្ចប់

១-ទទួលស្គាល់ពាក្យបណ្តឹងចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ របស់ដើមចោទឈ្មោះ [redacted] សុផល មានលក្ខណៈត្រឹមត្រូវតាមទំរង់ តែពុំស្របនិងគតិច្បាប់ ។

២-ទទួលស្គាល់ពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ លោកមេធាវីតំណាងដោយអាណត្តិអោយដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។ ប៉ុន្តែទទួលយកចំណុច(ក) នៃពាក្យសុំកែតម្រូវពាក្យបណ្តឹងប៉ុណ្ណោះ ។

៣-រំលាយកិច្ចសន្យាទិញ-លក់អចលនវត្ថុ(ដី) រវាងលោក[redacted]ធារិទ្ធ (ជាអ្នកទិញហៅភាគីក)និងលោក[redacted] គីមហេង លោក[redacted] សុផល(ជាអ្នកលក់ ហៅភាគីខ) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ចោល ។ ប៉ុន្តែមានអានុភាពអនុវត្តទៅលើឈ្មោះ[redacted]ធារិទ្ធ និងឈ្មោះ[redacted] សុផល តែប៉ុណ្ណោះ ដែលមានដីចំនួន១៣ហិកតា ។

៤-ទទួលស្គាល់កិច្ចសន្យាទិញ-លក់អចលនវត្ថុ(ដី) រវាងលោក[redacted]ធារិទ្ធ (ជាអ្នកទិញហៅភាគីក)និងលោក [redacted] គីមហេង លោក[redacted]សុផល(ជាអ្នកលក់ ហៅភាគីខ) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ទុកជាត្រឹមត្រូវតាមច្បាប់ ប៉ុន្តែបដិសេធន៍ចោលចំណុចទី២ , ៣ , ៤ , ៥ និងទី៦ ពាក្យបណ្តឹងតបរបស់ចុងចម្លើយ ។

៥-រឹបអូសប្រាក់កក់របស់ចុងចម្លើយចំនួន១៩.៦០០$ (មួយម៉ឺនប្រាំបួនពាន់ប្រាំមួយរយ)ដុល្លារអាមេរិក ឱ្យទៅជាប្រយោជន៍របស់ដើមចោទ ឈ្មោះ[redacted]សុផល តាមកិច្ចសន្យា ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

៦-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

ថ្ងៃព្រហស្បតិ៍៣រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
តាកែវ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**
ហត្ថលេខា និងត្រា[redacted]

**ចៅក្រម**
ហត្ថលេខា និងត្រា[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃព្រហស្បតិ៍៣រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
តាកែវ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤
**ក្រឡាបញ្ជី**

បានឃើញ
**ចៅក្រម**

[redacted]

[redacted]